ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
អគ្គលេខាធិការដ្ឋាន
លេខ:០១៧.ស.ជ.ណ.ក.ជ.អ.ច.

សេចក្តីប្រកាសព័ត៌មាន

ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងដើម្បីក្លាយជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ឱ្យបាននៅត្រឹមឆ្នាំ ២០៣០ និងក្នុងការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់យើងសម្រាប់ឆ្នាំ ២០១៥-២០២៥ រាជរដ្ឋាភិបាលកម្ពុជាកំពុងចាប់ផ្តើមពិនិត្យលើជម្រើសនានា ដើម្បីធ្វើទំនើបកម្មសេដ្ឋកិច្ចជាតិ សំដៅឈានឆ្ពោះទៅរកសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើចំណេះដឹង ដោយកាត់បន្ថយការពឹងផ្អែកលើវិស័យធនធានធម្មជាតិ និងលើកកម្ពស់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងការបង្កើតថ្មី ជាពិសេស កម្ពុជាចាំបាច់ត្រូវបំពេញតម្រូវការថាមពលនាពេលអនាគត និងសម្រេចឱ្យបានសន្តិសុខថាមពល ដោយបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបង្កឱ្យមានការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលខិតខំស្វែងរកប្រភពថាមពលជំនួស ជាពិសេស ថាមពលវារីអគ្គិសនី ថាមពលពន្លឺព្រះអាទិត្យ និងថាមពលខ្យល់។ យើងក៏បានចាប់ផ្តើមពិភាក្សាលើលទ្ធភាពក្នុងការទទួលផលប្រយោជន៍ពីថាមពលនុយក្លេអ៊ែរ នៅក្នុងរយៈពេលវែងផងដែរ។ យើងក៏មានចំណាប់អារម្មណ៍លើបច្ចេកវិទ្យានុយក្លេអ៊ែរ សម្រាប់ការប្រើប្រាស់ក្នុងវិស័យសុខាភិបាល ឧស្សាហកម្ម កសិកម្ម និងវិស័យដទៃទៀតនៃសេដ្ឋកិច្ចជាតិ។

ក្នុងស្មារតីនេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច) និងសាជីវកម្មថាមពលបរមាណូរដ្ឋ "រ៉ូហ្សាតុម" នៃសហព័ន្ធរុស្ស៊ី បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ចំនួនបី រួមមាន អនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលបរមាណូសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព អនុស្សរណៈនៃការយោគយល់ ស្តីពីការបង្កើតក្រុមការងាររួមកម្ពុជា-រុស្ស៊ី សម្រាប់កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលបរមាណូសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព និងអនុស្សរណៈនៃការយោគយល់ ស្តីពីការបង្កើតមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរនៅកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងសាធារណៈអំពីថាមពលនុយក្លេអ៊ែរ ជាពិសេស ក្នុងចំណោមយុវជនយើង។

ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់ទាំងនេះ និងដើម្បីពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ក.ជ.អ.ច. និងរ៉ូហ្សាតុម បានរៀបចំ "*កិច្ចប្រជុំលើកទី១ នៃក្រុមការងាររួមកម្ពុជា-រុស្ស៊ីសម្រាប់កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលបរមាណូសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព*" នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន ក.ជ.អ.ច និងឯកឧត្តម **ឌ្មីទ្រី ស្មៀតកូវ** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជាបានចូលរួមជាគណៈអធិបតីនៅក្នុងពិធីបើកកិច្ចប្រជុំនេះ ហើយនៅក្នុងការពិភាក្សាពេញអង្គមានតំណាងចូលរួមមកពីរ៉ូហ្សាតុម និងក្រុមការងារជាតិកម្ពុជា។ កិច្ចប្រជុំនេះមានគោលបំណង ៖ (១) ពិនិត្យសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហព័ន្ធរុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលបរមាណូសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ជាចុងក្រោយក្នុងកម្រិតបច្ចេកទេស (២) ពិភាក្សាលើបែបបទការងាររបស់ក្រុមការងាររួមកម្ពុជា-រុស្ស៊ី (៣) ពិភាក្សាលើការអនុវត្តអនុស្សរណៈនៃការយោគយល់ ស្តីពីការបង្កើតមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ និង (៤) ពិភាក្សាអំពីសកម្មភាពអាទិភាព នៅក្រោមអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលបរមាណូសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព។

ជាអាទិភាពដំបូង យើងមានបំណងធ្វើសហប្រតិបត្តិការជាមួយ រ៉ូហ្សាតុម និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ ដែលយើងសង្ឃឹមថា នឹងជួយពង្រីកចំណាប់អារម្មណ៍របស់យុវជនយើងលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ជាពិសេសលើមុខវិជ្ជារូបវិទ្យានុយក្លេអ៊ែរ និងបច្ចេកវិទ្យានុយក្លេអ៊ែរ។ ទន្ទឹមនឹងនេះ យើងគ្រោងពិភាក្សាបន្ថែមផងដែរអំពីការស្រាវជ្រាវ និងការបណ្តុះបណ្តាលរួមគ្នាក្នុងវិស័យថាមពលនុយក្លេអ៊ែរ និងកសាងសមត្ថភាពរបស់យើងលើមុខវិជ្ជា រូបវិទ្យានុយក្លេអ៊ែរ សុវត្ថិភាពនុយក្លេអ៊ែរ និងវិទ្យុសកម្ម ការឆ្លើយតបបន្ទាន់ ការគ្រប់គ្រងសំណល់វិទ្យុសកម្ម និងការវាយតម្លៃផលប៉ះពាល់វិទ្យុសកម្ម។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦

__ចំពោះព័ត៌មានបន្ថែម សូមទាក់ទង__៖
លោក ទិន ពន្លក អគ្គលេខាធិការ ក.ជ.អ.ច. និង
សហប្រធានក្រុមការងាររួម
ទូរស័ព្ទ៖ +855 12 915 351
អ៊ីម៉ែល៖ ETAP@online.com.kh